ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
មន្ទីរធម្មការ និង សាសនា
ខេត្ត កំពង់ធំ

លេខ: ២១៥/១២ មធស.សណន

## សេចក្តីណែនាំ
## ស្តីពីការចងទង់ព្រះពុទ្ធសាសនាក្នុងពិធីបុណ្យទានផ្សេងៗ

កន្លងមក មន្ទីរធម្មការ និង សាសនាខេត្តសង្កេតឃើញថា មានពុទ្ធបរិស័ទ ព្រមទាំងស្ថាប័ន និង វត្តអារាម មួយចំនួន បានចងទង់ព្រះពុទ្ធសាសនាក្នុងពិធីបុណ្យទានផ្សេងៗបានត្រឹមត្រូវហើយ ប៉ុន្តែនៅមានពុទ្ធបរិស័ទ និង វត្តអារាមមួយចំនួន មិនទាន់ចងបានត្រឹមត្រូវទៅតាមគោលការណ៍ និង អត្ថន័យនៃទង់ព្រះពុទ្ធសាសនានៅឡើយ ។ ដើម្បីចូលរួមកែលំអ និង ពង្រីកចំណេះដឹងអំពីអត្ថន័យនៃទង់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ឲ្យបានទូលំទូលាយនោះ មន្ទីរធម្មការនិងសាសនាខេត្ត សូមធ្វើការបកស្រាយអត្ថន័យ នៃទង់ព្រះពុទ្ធសាសនា ដូចតទៅ ៖

ទង់ព្រះពុទ្ធសាសនា មានពណ៌ចំនួន៦(ឆព្វណ្ណរង្សី) គឺ:

១-**ពណ៌ខៀវ** គឺតំណាងឲ្យកាលដែលព្រះអង្គ ទ្រង់សោយព្រះជាតិជាព្រះបាទស្រីពិភស្រ្ត។ ក្នុងកាលនោះ គឺព្រះឥន្ទបានក្លែងខ្លួនធ្វើជាព្រាហ្មណ៍ មកសុំព្រះនេត្រទាំងគូរបស់ព្រះអង្គ ។ ព្រះអង្គក៏ឆ្កៀលព្រះនេត្រខ្លួនឯងឲ្យទៅព្រាហ្មណ៍ ។

២-**ពណ៌លឿង** គឺតំណាងឲ្យព្រះអង្គ កាលដែលព្រះអង្គទ្រង់សោយព្រះជាតិជាវៃបណ្ឌិត ព្រះឥន្ទបានក្លែងខ្លួនធ្វើជាជាងមាស ហើយវៃបណ្ឌិត ក៏បានអារសាច់ខ្លួនឯងឲ្យជាងមាសនោះ ដើម្បីផ្សំធ្វើជាផែបិទព្រះពុទ្ធរូប ។

៣-**ពណ៌ក្រហម** តំណាងឲ្យព្រះអង្គ កាលដែលព្រះអង្គទ្រង់សោយព្រះជាតិជាមាណពឈ្មោះ បទុមកុមារ ក៏បានកាត់បេះដូងខ្លួនឲ្យទៅពេទ្យ ដើម្បីផ្សំថ្នាំឲ្យមាតា ។

៤-**ពណ៌ស** តំណាងឲ្យព្រះអង្គ កាលដែលព្រះអង្គទ្រង់សោយព្រះជាតិជាវេស្សន្តរ ទ្រង់ប្រទានដំរីមង្គល ដល់ព្រាហ្មណ៍ ។

៥-**ពណ៌ហង្សបាទ** តំណាងឲ្យព្រះអង្គ កាលដែលព្រះអង្គទ្រង់សោយព្រះជាតិជាវិទ្យាធរ ទ្រង់អារសាច់ឲ្យយក្សស៊ី ដើម្បីប្តូរយកមាតាមកវិញ ។

៦-**ពណ៌ចម្រុះ** តំណាងឲ្យព្រះអង្គ កាលដែលព្រះអង្គទ្រង់សោយព្រះជាតិជាសត្វទន្សាយ ឈ្មោះ សោមបណ្ឌិត មានសទ្ធាចង់បំពេញទានបារមី បានលោតចូលភ្លើងដើម្បីបូជាសាច់ឈាមដល់ឥន្ទព្រាហ្មណ៍ ។

ដូច្នេះរាល់ការចងទង់ព្រះពុទ្ធសាសនា ត្រូវចងឲ្យបានត្រឹមត្រូវ គឺត្រូវចងដាក់ពណ៌ខៀវនៅខាងលើ ព្រោះពណ៌ខៀវគឺជាពណ៌ទី១ ក្នុងចំណោមពណ៌ទាំង៦ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណ និង អស់លោក លោកស្រី ព្រមទាំងពុទ្ធបរិស័ទទាំងអស់ជ្រាប និង ចូលរួមអនុវត្តឲ្យបានសមស្របតាមខ្លឹមសារខាងលើ ក្នុងឋានៈជាអ្នកកាន់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ។

កំពង់ធំ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២
ប្រធានមន្ទីរ

គាន់_តៃប្រាន់

**ចម្លងជូន**
-ក្រសួងធម្មការ និង សាសនា
-គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
-ក្រុមប្រឹក្សាខេត្ត
-សាលាខេត្ត
-សាលាគណៈខេត្ត
"ដើម្បីថ្វាយ-ប្រគេន និង ជូនជ្រាប"
-គ្រប់មន្ទីរ អង្គភាពជុំវិញខេត្ត
-គ្រប់សាលាស្រុក/ក្រុង
-ការិយាល័យធម្មការ និង សាសនាស្រុក/ក្រុង
-សាលាអនុគណស្រុក/ក្រុង
-គ្រប់វត្ត អារាម
"ដើម្បីប្រគេន-ជូនជ្រាប និង អនុវត្តន៍"
-ឯកសារ-កាលប្បវត្តិ